**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល**

ថ្ងៃចន្ទ ២រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

លេខ ១២២៦ ប.ជ.ស

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបម្រើសេវាបើកផ្តល់ប្រាក់គោលនយោបាយរបបសន្តិសុខសង្គមសម្រាប់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល នៅរាជធានីភ្នំពេញ

បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល "ប.ជ.ស." មានកិត្តិយស សូមគោរពជម្រាបជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុកនៅរាជធានីភ្នំពេញ បានជ្រាបថា ប្រាក់គោលនយោបាយសោធនសម្រាប់ខែធ្នូ ឆ្នាំ២០១៨ នឹងត្រូវបានបើកផ្តល់ចាប់ពីថ្ងៃ **អង្គារ ៣រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង ១២:០០ នាទី តទៅ** តាមប្រព័ន្ធធនាគារ កាណាឌីយ៉ា ក.អ នៅគ្រប់សាខានៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវយកភ្ជាប់មកជាមួយនូវសៀវភៅគណនីរបស់ធនាគារ កាណាឌីយ៉ា ក.អ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

ចំពោះប្រាក់គោលនយោបាយរបបសន្តិសុខសង្គមរបស់សពនិវត្តជន របស់សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងប្រាក់គោលនយោបាយប្រចាំខែសម្រាប់អ្នកនៅក្នុងបន្ទុករបស់សពនិវត្តជន អ្នកនៅក្នុងបន្ទុករបស់សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងកូនកំព្រារបស់សពមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំបើកជូនដល់គេហដ្ឋាន ឬតាមសាលាសង្កាត់ សាលាខណ្ឌ នៅរាជធានីភ្នំពេញ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុកទាំងអស់នៅរាជធានីភ្នំពេញ មេត្តាជ្រាបជាព័ត៌មាន ។ ក្នុងករណីនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ មានជំងឺមិនអាចទៅបើកប្រាក់សោធននៅធនាគារបាន ឬទទួលមរណភាព សូមអ្នកនៅក្នុងបន្ទុក និងអ្នកដែលបានទទួលសិទ្ធិបើកប្រាក់សោធនប្រចាំខែ មេត្តាជូនដំណឹងជាបន្ទាន់មកបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល តាមទូរស័ព្ទលេខ : **023 726 491 - 023 987 512 - 023 987 523** ឬតាមរយៈ **E-mail: info@nssfc.gov.kh** ដោយសេចក្តីអនុគ្រោះ ។

**បញ្ជាក់** : ប.ជ.ស. មានគេហទំព័រ **www.nssfc.gov.kh**
**Facebook page: បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល - បជស**
**(https://www.facebook.com/nssfc4)**

**អគ្គនាយក**

**ម៉ែន_សុបិត្រ**

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រុមប្រឹក្សាភិបាល នៃ ប.ជ.ស.
- សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"
- ធនាគារ កាណាឌីយ៉ា ក.អ

"ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល** *ថ្ងៃចន្ទ ២រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*

លេខ ១២២៨ ប.ជ.ស *រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៨*

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបម្រើសេវាបើកផ្តល់ប្រាក់គោលនយោបាយរបបសន្តិសុខសង្គមសម្រាប់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល

បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល "ប.ជ.ស." មានកិត្តិយស សូមគោរពជម្រាបជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុក នៅតាមបណ្តាខេត្ត រួមមាន ÷

| | | |
|---|---|---|
| ១ - ខេត្តកណ្តាល | ៩ - ខេត្តបន្ទាយមានជ័យ | ១៧ - ខេត្តក្រចេះ |
| ២ - ខេត្តកំពង់ចាម | ១០ - ខេត្តពោធិ៍សាត់ | ១៨ - ខេត្តស្ទឹងត្រែង |
| ៣ - ខេត្តត្បូងឃ្មុំ | ១១ - ខេត្តកំពង់ឆ្នាំង | ១៩ - ខេត្តមណ្ឌលគិរី |
| ៤ - ខេត្តស្វាយរៀង | ១២ - ខេត្តកំពង់ស្ពឺ | ២០ - ខេត្តរតនគិរី |
| ៥ - ខេត្តព្រៃវែង | ១៣ - ខេត្តព្រះសីហនុ | ២១ - ខេត្តឧត្តរមានជ័យ |
| ៦ - ខេត្តកំពង់ធំ | ១៤ - ខេត្តកំពត | ២២ - ខេត្តប៉ៃលិន |
| ៧ - ខេត្តសៀមរាប | ១៥ - ខេត្តកែប | ២៣ - ខេត្តព្រះវិហារ |
| ៨ - ខេត្តបាត់ដំបង | ១៦ - ខេត្តតាកែវ | ២៤ - ខេត្តកោះកុង |

សូមមេត្តាជ្រាបថា ប្រាក់គោលនយោបាយសោធនសម្រាប់ខែធ្នូ ឆ្នាំ២០១៨ នឹងត្រូវបានបើកផ្តល់ចាប់ពីថ្ងៃ អង្គារ ៣រោច **ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង ១៤ :០០ តទៅ** តាមប្រព័ន្ធធនាគារ អេស៊ីលីដា ភីអិលស៊ី នៅគ្រប់សាខានៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវយកភ្ជាប់មកជាមួយនូវសៀវភៅគណនីរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

ចំពោះប្រាក់គោលនយោបាយរបបសន្តិសុខសង្គមរបស់សពនិវត្តជន សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងប្រាក់គោលនយោបាយប្រចាំខែសម្រាប់អ្នកនៅក្នុងបន្ទុករបស់សពនិវត្តជន អ្នកនៅក្នុងបន្ទុករបស់សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងកូនកំព្រារបស់សពមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំបើកជូនដល់គេហដ្ឋាន ឬតាមសាលាឃុំ សង្កាត់នៅតាមបណ្តាខេត្តនីមួយៗ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុកនៅតាមបណ្តាខេត្ត មេត្តាជ្រាបជាព័ត៌មាន ។ ក្នុងករណីនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ មានជំងឺមិនអាចទៅបើកប្រាក់សោធននៅធនាគារបាន ឬទទួលមរណភាព សូមអ្នកនៅក្នុងបន្ទុក និងអ្នកដែលបានទទួលសិទ្ធិបើកប្រាក់សោធនប្រចាំខែ មេត្តាជូនដំណឹងជាបន្ទាន់មកបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធទូរស័ព្ទលេខ **023 726 491 - 023 987 512 - 023 987 523** ឬតាមរយៈ **E-mail: info@nssfc.gov.kh** ដោយសេចក្តីអនុគ្រោះ ។

**បញ្ជាក់ :** ប.ជ.ស. មានគេហទំព័រ **www.nssfc.gov.kh**
**Facebook page:** បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល - បជស
**(https://www.facebook.com/nssfc4)**

**នាយក**

**ម៉ែន_សុបិត្រ**

**<u>ចម្លងជូន</u> :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រុមប្រឹក្សាភិបាល នៃ ប.ជ.ស.
- គ្រប់សាលាខេត្ត
  "ដើម្បីជូនជ្រាប"
- ធនាគារ អេស៊ីលីដា ភីអិលស៊ី
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ